# សោមទត្តជាតក



*ព្រះសាស្តាកាលស្តេចគង់នៅវត្តជេតពន ទ្រង់ប្រារព្ធលោកតាចាស់មួយរូប បាន ត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា* **យោ មំ បុរេ បច្ចុឌ្ឌេតិ** *ដូច្នេះជាដើម ។*

*បានឮមកថា លោកតានោះបានបំបួសសាមណេរមួយរូប, សាមណេរនោះ ជាអ្នក មានឧបការៈដល់លោក, (ខាងក្រោយមក) សាមណេរនោះធ្វើកាលកិរិយាដោយរោគយ៉ាង ណាមួយ ។ កាលសាមណេរស្លាប់ហើយ លោកតាចាស់យំសោកបរិទេវនាការត្រាច់ទៅ ។ ភិក្ខុទាំងឡាយឃើញលោកតានោះហើយ និយាយជំនុំគ្នាក្នុងសាលាធម្មសភាថា ម្នាល អាវុសោ លោកតាចាស់ឯណោះ កាលសាមណេរ (របស់ខ្លួន) ស្លាប់ហើយ យំសោកបរិទេវ-នាការត្រាច់ទៅ, លោកប្រហែលជាវៀរចាកមរណស្សតិកម្មដ្ឋានហើយ ។ ព្រះសាស្តាយាង មក ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយអង្គុយនិយាយគ្នាពី រឿងអ្វី ? កាលពួកភិក្ខុទូលថា ដោយរឿងនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិន*

*មែនតែក្នុងកាលឥឡូវនេះទេ សូម្បីក្នុងកាលមុន លោកតាចាស់នោះ ក៏យំសោកនឹងសាមណេរដែលស្លាប់ទៅហើយនោះដែរ ។ រួចទ្រង់នាំយកអតីតនិទានមកថា*

*ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី, ព្រះពោធិសត្វជាព្រះឥន្ទគ្រប់គ្រងនៅតាវត្តិង្ស ។ គ្រានោះ មានព្រាហ្មណមហាសាលដែលជាអ្នកស្រុកកាសីម្នាក់ លះបង់កាម ចូលទៅកាន់ព្រៃហិមពាន្ត បួសជាឥសី ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយការស្វែងរកមើមឈើនិងផលាផលក្នុងព្រៃ ។*

*ថ្ងៃមួយ កាលតាបសទៅស្វែងរកផលាផល បានឃើញកូនដំរីមួយ ហើយនាំមកកាន់អាស្រមរបស់ខ្លួន តាំងកូនដំរីនោះទុកដូចជាកូន ដាក់ឈ្មោះឲ្យថា* ***សោមទត្ត*** *ចិញ្ចឹមកូនដំរីឲ្យស៊ីស្មៅនិងស្លឹកឈើ ។ កូនដំរីនោះធំឡើងហើយ មានសរីរៈធំ ។ ថ្ងៃមួយ វាស៊ីអាហារច្រើនពេក អាហារមិនរលួយ ធ្វើឲ្យវាដល់នូវភាពទុព្វល ។ តាបសទុកវាឲ្យនៅជិតអាស្រម ហើយគាត់ទៅរកផលាផល, កូនដំរីក៏ធ្វើកាលកិរិយាក្នុងពេលដែលគាត់មិនទាន់មកវិញនោះឯង ។ តាបសនាំផលាផលមកហើយ គាត់សង្ស័យថា ក្នុងថ្ងៃដទៃៗ កូនរបស់យើង តែងមកធ្វើការទទួល, តែថ្ងៃនេះ មិនឃើញសោះ វាទៅណាហើយអេះ ដូច្នេះកាលនឹងបរិទេវនាការ (ទួញយំ) ទើបពោលគាថាទី ១ ថា*

**យោ មំ បុរេ បច្ចុឌ្ឌេតិ, អរញ្ញេ ទូរមាយតោ;**
**សោ ន ទិស្សតិ មាតង្គោ, សោមទត្តោ កុហឹ គតោ។**

***កាលពីមុខដំរីណា មកអំពីចម្ងាយ ទទួលអាត្មាអញក្នុងព្រៃ (ឥឡូវនេះ) ដំរីឈ្មោះសោមទត្តនោះ ទៅក្នុងទីណា បានជាបាត់ មិនឃើញមក ។***

*កាលបរិទេវនាការយ៉ាងនេះហើយ តាបសដើរមក ក៏ឃើញកូនដំរីនោះដួលនៅចុងទីចង្រ្កម គាត់ចាប់កកូនដំរី កាលទួញយំ ទើបពោលគាថាទី ២ ថា*

អយំ វា សោ មតោ សេតិ, អល្លសិង្គំវ វច្ឆិតោ;
ភូម្យា ឆិបតិតោ សេតិ, អមរា វត កុញ្ជរោ។

*ដំរីដេកស្លាប់នេះ គឺដំរីនេះឯង ដំរីសោមទត្តដួលដេកលើផែនដី ដូចជាត្រួយជ្រៃ ដែលបុគ្គលក្តិចហើយ ដំរី ( នោះ ) មិនទាន់ស្លាប់ទេហ្ន៎ ។*

*ខណៈនោះ សក្កទេវរាជប្រមើលមើលសត្វលោក ឃើញតាបសនោះ ទ្រង់គិតថា តាបសនេះលះបង់កូនប្រពន្ធហើយបួស ឥឡូវនេះ មកសម្គាល់កូនដំរីថាជាកូនខ្លួនហើយ ទួញយំទៅវិញ យើងនឹងធ្វើតាបសនេះឲ្យសង្វេគ ឲ្យគាត់មានសតិឡើងវិញ គិតដូច្នេះហើយ ទ្រង់យាងមកកាន់អាស្រមតាបស ឋិតនៅលើអាកាស ពោលគាថាទី ៣ ថា*

អនគារិយុបេតស្ស, វិប្បមុត្តស្ស តេ សតោ;
សមណស្ស ន តំ សាធុ, យំ បេតមនុសោចសិ។

*លោកសោកស្តាយដំរីណា ដែលស្លាប់បាត់ទៅហើយ ការសោកស្តាយដំរីនោះ មិនសមគួរដល់លោក ដែលចូលមកកាន់ផ្នួស ជាសមណៈមានចិត្តរួចស្រឡះសោះឡើយ ។*

*តាបសស្តាប់ពាក្យសក្កទេវរាជហើយ ពោលគាថាទី ៤ ថា*

សំវាសេន ហវេ សក្ក, មនុស្សស្ស មិគស្ស វា;
ហទយេ ជាយតេ បេមំ, តំ ន សក្កា អសោចិតុំ។

*បពិត្រសក្កៈ សេចក្តីស្រឡាញ់ រមែងកើតក្នុងហឫទ័យ របស់មនុស្សក្តី ម្រឹគក្តី ដោយសារធ្លាប់នៅជាមួយគ្នា អាត្មាមិនអាចមិនសោកស្តាយដំរីនោះបានឡើយ ។*

*ពេលនោះ ស្តេចសក្កៈកាលនឹងឲ្យឱវាទតាបស ទើបពោល ២ គាថា ថា*

មតំ មរិស្សំ រោទន្តិ, យេ រុទន្តិ លបន្តិ ច;
តស្មា ត្វំ ឥសិ មា រោទិ, រោទិតំ មោឃមាហុ សន្តោ។

*សត្វទាំងឡាយណា យំទួញរៀបរាប់ សត្វទាំងឡាយនោះ តែងយំរកសត្វដែលស្លាប់បាត់ទៅហើយ ឬក៏សត្វដែលបម្រុងនឹងស្លាប់ នៃឥសី ព្រោះហេតុនោះ លោកកុំយំឡើយ ពួកសប្បុរសពោលថា ការយំ ជាធម្មជាតឥតអំពើទេ ។*

កន្ទិតេន ហវេ ព្រហ្មេ, មតោ បេតោ សមុដ្ឋហេ;
សព្ពេ សង្គម្ម រោទាម, អញ្ញមញ្ញស្ស ញាតកេ។

*បពិត្រព្រហ្ម ប្រសិនបើបុគ្គលដែលស្លាប់ទៅកាន់បរលោកហើយ គប្បីរស់ឡើងវិញ ដោយការយំទួញ ពួកយើងទាំងអស់ក៏គួរប្រជុំគ្នាយំរកពួកញាតិ នៃគ្នានឹងគ្នាដែរ ។*

*តាបសស្តាប់ពាក្យសក្កទេវរាជហើយ មានសតិឡើងវិញ ជាអ្នកប្រាសចាកសេចក្តីសោក ជូតទឹកភ្នែក ហើយពោលគាថាដ៏សេសសរសើរសក្កទេវរាជថា*

អាទិត្តំ វត មំ សន្តំ, ឃតសិត្តំវ បាវកំ;
វារិនា វិយ ឱសិញ្ចំ, សព្ពំ និព្ពាបយេ ទរំ។

*អ្នកបានស្រោចខ្ញុំ ដែលត្រូវភ្លើង គឺសេចក្តីសោក កំពុងឆេះសព្វ ឲ្យត្រជាក់ត្រជំ រំលត់នូវក្រវល់ក្រវាយទាំងអស់បាន ដូចជាបុគ្គលយកទឹកស្រោចលត់នូវភ្លើង ដែលកំពុងឆេះនូវផ្ទាំងខ្លាញ់ ។*

អព្ពហី វត មេ សល្លំ, យមាសិ ហទយស្សិតំ;
យោ មេ សោកបរេតស្ស, បុត្តសោកំ អបានុទិ។

*អ្នកបានបន្ទោបង់សេចក្តីសោក ព្រោះកូនរបស់ខ្ញុំ ដែលត្រូវសេចក្តីសោក កំពុងគ្របសង្កត់ ឈ្មោះថាបានដកចោលនូវសរ គឺសេចក្តីសោក ដែលអាស្រ័យនៅក្នុងហឫទ័យនៃខ្ញុំបាន ។*

សោហំ អព្ពូឡ្ហសល្លោស្មិ, វីតសោកោ អនាវិលោ;
ន សោចាមិ ន រោទាមិ, តវ សុត្វាន វាសវ។

*បពិត្រវាសវៈ ខ្ញុំនោះឈ្មោះថា មានសរដកចោលហើយ ប្រាសចាកសេចក្តីសោកហើយ ឥតមានចិត្តល្អក់ ខ្ញុំលែងសោកស្តាយ លែងយំ ព្រោះបានស្តាប់ ( នូវពាក្យរបស់អ្នក)។*

*សក្កទេវរាជឲ្យឱវាទតាបសយ៉ាងនេះហើយ ក៏ទៅកាន់លំនៅរបស់ខ្លួនវិញ ។*

*ព្រះសាស្តានាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា*

តទា ហត្ថិទោតកោ សាមណេរោ អហោសិ *កូនដំរីក្នុងកាលនោះបានមកជាសាមណេរ*

តាបសោ មហាល្លកោ *តាបសបានមកជាលោកតាចាស់*

សក្កោ បន អហមេវ អហោសិំ *ចំណែកសក្កទេវរាជ គឺតថាគតនេះឯង ។*

*សោមទត្តជាតក ចប់។*

*(ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក សត្តកនិបាត គន្ធារវគ្គ បិដកលេខ ៥៩ ទំព័រ ៩៨)*

*ថ្ងៃព្រហស្បតិ៍ ១៥ រោច ខែផល្គុន ឆ្នាំច សំរិទ្ធិស័ក ច.ស. ១៣៨០ ម.ស. ១៩៤០*

*ថ្ងៃទី ៤ ខែមេសា ព.ស. ២៥៦២ គ.ស.២០១៩*

*ដោយស.ដ.វ.ថ.*